## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ




# សៀវភៅរបាយការណ៍
# លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ
# ខេត្តស្វាយរៀង

**រៀបចំដោយៈ**

នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ
វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ

**រាជធានីភ្នំពេញ ខែធ្នូ ឆ្នាំ២០២១**

# មាតិកា


បុព្វកថា........................................................................................................i

អារម្ភកថា ....................................................................................................ii

**ជំពូកទី១** ....................................................................................................iii

សេចក្តីផ្តើម....................................................................................................iii

១.១. សេចក្តីផ្តើម ......................................................................................... ១

១.២. គោលបំណង........................................................................................... ១

១.៣. វិធីសាស្រ្តប្រមូលទិន្នន័យ ......................................................................២

១.៤. ការកែច្នៃទិន្នន័យ .....................................................................................២

១.៤.១ ផែនទីចំនួនស្រុកក្នុងខេត្តស្វាយរៀង.......................................... ២

១.៤.២ ផែនទីចំនួនខេត្តដែលបានប្រមូលទិន្នន័យ.................................... ៣

**ជំពូកទី២** ....................................................................................................... ៤

វិភាគទិន្នន័យ .................................................................................................. ៤

**២.១. ព័ត៌មានប្រជាស្រ្ត.** ............................................................................................ ៥

២.១.១ . ចំនួនប្រជាជន និងគ្រួសារ ....................................................................... ៥

២.១.២. ព័ត៌មានប្រជាជន ..................................................................................... ៦

២.១.៣ . ការផ្លាស់ប្តូរទីលំនៅ...............................................................................៧

២.១.៤ .លំនៅដ្ឋាន.............................................................................................. ១០

២.១.៥ .សម្ភារ ឬបរិក្ខារដឹកជញ្ជូន .................................................................... ១៥

**២.២. អត្រាកំណើត និងមរណភាព**.................................................................... ១៦

២.២.១ . អត្រាកំណើត........................................................................................ ១៦

២.២.២ មរណភាព ............................................................................................ ១៧

**២.៣. ពិការភាពនិងបុគ្គលគ្មានអ្នកមើលថែ** ...................................................... ១៩

**២.៤ ការប្រើប្រាស់ទឹក និងអនាម័យ**.....................................................................២១

**២.៥. បរិស្ថាន និងគ្រោះធម្មជាតិ** .........................................................................២៥

**២.៧. សន្តិសុខសង្គម និងសេដ្ឋកិច្ច**....................................................................២៧

២.៧.១. អសន្តិសុខសង្គម...................................................................................២៧

២.៧.២.សេដ្ឋកិច្ចគ្រួសារ.....................................................................................៣០

**២.៨. វិស័យអប់រំ និងសេវាសង្គម**........................................................ ៣៣
២.៨.១. ផ្នែកសិក្សាអប់រំ ........................................................ ៣៣
**២.៩ ការស្ថាបនាផ្លូវគមនាគមន៍** ........................................................ ៣៦
**២.១០ . សុខាភិបាល** ........................................................ ៣៦
២.១០. ១. សេវាកម្មសុខភាព........................................................ ៣៦
២.១០. ២. ប្រេវ៉ាឡង់ជំងឺសំខាន់ៗ . ........................................................ ៣៩
២.១០.៣. គ្រួសារផ្ទុកមេរោគអេដស៍ ឬជំងឺអេដស៍ និងកុមារកំព្រា........................................................ ៤២
**២.១១.កសិកម្ម** ........................................................ ៤៤
២.១១.១ ការកាន់កាប់ក្បាលដីកសិកម្ម និងដីជុំវិញលំនៅដ្ឋាន........................................................ ៤៤
២.១១.២. ការកាន់កាប់ផ្ទៃដីកសិកម្ម ........................................................ ៤៥
២.១១.៣ . ប្រភេទផ្ទៃដីកសិកម្ម ........................................................ ៤៥
២.១១.៤ .ការស្រោចស្រពផ្ទៃដីកសិកម្ម ........................................................ ៤៦
២.១១.៥ .ការប្រើប្រាស់ជីគីមី និងជីសរីរាង្គលើផ្ទៃដីកសិកម្ម ........................................................ ៤៨
២.១១.៦. ការប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃ ថ្នាំសម្លាប់ស្មៅ និងថ្នាំសម្លាប់ផ្សិតលើផ្ទៃដីកសិកម្ម...........៤៨
២.១១.៧. ការចិញ្ចឹមបសុសត្វ និងបសុបក្សី ........................................................៤៩
**ជំពូកទី៣**........................................................ ៥៣
**សន្និដ្ឋាន និងអនុសាសន៍**........................................................ ៥៣
៣.១. សន្និដ្ឋាន........................................................ ៥៤
៣.២. អនុសាសន៍........................................................ ៥៤
ឯកសារភ្ជាប់៖ តារាងទិន្នន័យសង្ខេបស្ថិតិថ្នាក់ក្រោមជាតិ ........................................................ ៥៥
តារាងកម្រោងសំណួរស្ថិតិថ្នាក់ក្រោមជាតិ........................................................៥៨

# បុព្វកថា

ខ្ញុំមានសេចក្តីសោមនស្សរីករាយ នឹងបង្ហាញជូនរបាយការណ៍លទ្ធផលវិភាគ ស្តីពីទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិជំហានទី៥ ដោយផ្អែកលើទិន្នន័យដែលបានប្រមូលចំនួន ១ ខេត្ត គឺខេត្តស្វាយរៀង។ របាយការណ៍នេះបានប្រមូលនូវទិន្នន័យសំខាន់ៗរួមមាន៖ ស្ថិតិប្រជាសាស្ត្រ ស្ថិតិកសិកម្ម ស្ថិតិសេដ្ឋកិច្ច និងស្ថិតិសង្គមកិច្ច សម្រាប់ជាមូលដ្ឋានគ្រឹះក្នុងការកសាងផែនការ រៀបចំគោលនយោបាយ និងកម្មវិធីផ្សេងៗ ដើម្បីអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ ស្របតាមកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ។

ខ្ញុំសូមថ្លែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅដល់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានសម្រេចឱ្យក្រសួងផែនការបង្កើតនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នេះឡើងតាមអនុក្រឹត្យ លេខ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ កន្លងមក ។

សូមថ្លែងអំណរគុណដល់ ឯកឧត្តម **ហោ ដារិទ្ធ** រដ្ឋលេខាធិការ ក្រសួងផែនការ លោកជំទាវ **ហង់ លីណា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ដែលបានដឹកនាំ និងសម្របសម្រួលការងារនេះតាំងពីចាប់ផ្តើម ដោយមានជំនួយការពីឯកឧត្តមបណ្ឌិត **ម៉េង គីមហ៊ី** និងឯកឧត្តម **ពេជ្រ ពោធី** អគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ ទទួលបន្ទុកនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ ឯកឧត្តម **ចាន់ សំអាត** ប្រធាននាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ លោក លោកស្រី អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យ ព្រមទាំងមន្ត្រីទាំងអស់ដែលនៅក្នុងនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ។

សូមថ្លែងអំណរគុណដល់ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តស្វាយរៀង ឯកឧត្តមប្រធានមន្ទីរផែនការខេត្ត និងសហការីនៃ ខេត្តស្វាយរៀង ដូចបានរៀបរាប់ខាងលើ ដែលបានជួយសហការយ៉ាងសកម្មនៅក្នុងអំឡុងពេលចុះស្រង់ទិន្នន័យជាក់ស្តែង។

ខ្ញុំសង្ឃឹមថា អ្នករៀបចំគោលនយោបាយ អ្នកធ្វើផែនការសម្រាប់អភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ន អង្គការជាតិ អន្តរជាតិ អ្នកស្រាវជ្រាវ និងសាធារណៈជនទូទៅ នឹងប្រើប្រាស់របាយការណ៍លទ្ធផលវិភាគ ស្តីពីទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិជំហានទី៥ ដ៏មានសារៈសំខាន់នេះ ៕

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងផែនការ**

ភ្នំពេញ កម្ពុជា

ខែធ្នូ ឆ្នាំ២០២១

**កិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន**

# អារម្ភកថា

ការបោះពុម្ពផ្សាយសៀវភៅលើកទី៥ នៃរបាយការណ៍លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ ដែលបានផលិតឡើងដោយ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ដោយមានការសហការពីមន្ទីរផែនការខេត្តស្វាយរៀង ។ សៀវភៅនេះផ្តល់នូវទិន្នន័យសំខាន់ៗមួយចំនួនរួមមាន៖ ស្ថិតិប្រជាសាស្រ្ត ស្ថិតិកសិកម្ម ស្ថិតិសេដ្ឋកិច្ច និង ស្ថិតិសង្គមកិច្ច ហើយទិន្នន័យនេះសម្រាប់យកមកបម្រើការកសាងផែនការ រៀបចំគោលនយោបាយ និងកម្មវិធីផ្សេងៗ ដើម្បីអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ ។

ការបោះពុម្ពផ្សាយសៀវភៅនេះមានតារាងជាតួលេខ និងក្រាហ្វិកដែលមានការវិភាគអធិប្បាយខ្លីៗ និងអាចប្រើប្រាស់ជាប្រភពទិន្នន័យព័ត៌មាន សម្រាប់អ្នកប្រើប្រាស់គ្រប់រូបដែលមានចំណាប់អារម្មណ៍ទៅលើទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ។ ទិន្នន័យនៅក្នុងសៀវភៅនេះត្រូវបានផលិតឡើងដំបូងដោយ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ សហការជាមួយមន្ទីរផែនការខេត្ត ដោយជំហានទី១ បានចុះស្រង់ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិចំនួន ៥ ខេត្តរួចមាន៖ ខេត្តបន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ ជំហានទី២ បានចុះស្រង់ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិចំនួន ៤ ខេត្តដែលស្ថិតនៅតំបន់ឆ្នេរសមុទ្រមាន៖ ខេត្តកែប កំពត កោះកុង និងខេត្តព្រះសីហនុ ជំហានទី៣ បានចុះស្រង់ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិចំនួន ៥ ខេត្ត៖ ខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី និងខេត្តព្រះវិហារ ជំហានទី៤ បានចុះស្រង់ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិចំនួន ២ ខេត្តមាន៖ ខេត្តតាកែវ ខេត្តកណ្តាល សម្រាប់ឆ្នាំ២០១៩ និងជំហានទី៥ នេះ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិបានបន្តចុះស្រង់ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិបានចំនួន ១ ខេត្តទៀត គឺខេត្តស្វាយរៀងសម្រាប់ឆ្នាំ២០២០ ។

ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងអរគុណចំពោះក្រុមការងារនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ និងមន្ទីរផែនការខេត្តស្វាយរៀង ដែលបានចូលរួមចំណែកយ៉ាងធំធេង ក្នុងការរៀបចំចងក្រងបោះពុម្ពនូវរបាយការណ៍លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិដ៏មានសារៈសំខាន់ជាលើកទី៥នេះ ។៕

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជាអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ**

ភ្នំពេញ កម្ពុជា

ខែធ្នូ ឆ្នាំ២០២១

**ហង់ លីណា**

# ជំពូកទី១

# សេចក្តីផ្តើម

## ១.១. សេចក្តីផ្តើម

គម្រោងគាំទ្រស្ថិតិថ្នាក់ក្រោមជាតិ គឺជាគម្រោងថ្មីមួយដែលវិទ្យាស្ថានជាតិស្ថិតិបានរៀបចំឡើងដើម្បីប្រមូលទិន្នន័យស្ថិតិនៅថ្នាក់មូលដ្ឋាន និងធ្វើការវិភាគលើលទ្ធផលទាំងនោះស្របតាមការធ្វើវិមជ្ឈការ និងសហវិមជ្ឈការសម្រាប់ថ្នាក់ក្រោមជាតិ។

ស្ថិតិដែលត្រូវប្រមូលពីថ្នាក់មូលដ្ឋានដើម្បីយកមកចងក្រងវិភាគរួមមាន៖ ស្ថិតិប្រជាសាស្ត្រ ស្ថិតិកសិកម្ម ស្ថិតិសេដ្ឋកិច្ច និងស្ថិតិសង្គមកិច្ច។ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ គឺជាអ្នកអនុវត្តគម្រោងនេះដោយផ្ទាល់ ដែលស្របតាមភារកិច្ចរបស់នាយកដ្ឋាន និងតាមសេចក្តីសម្រេចដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ស្នើឲ្យបង្កើតនាយកដ្ឋាននេះឡើងតាមអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤។

ប្រទេសកម្ពុជាបានបែងចែកជា៤តំបន់សំខាន់ៗគឺ តំបន់វាលទំនាប តំបន់បឹងទន្លេសាប តំបន់ឆ្នេរ និងតំបន់ខ្ពង់រាប និងតំបន់ភ្នំ ។ នៅឆ្នាំ២០២០ ជំហានទី៥ នេះដោយសារមានការរាតត្បាតជំងឺកូវីដ១៩ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ បានជ្រើសរើសខេត្តចំនួន ១ ដើម្បីយកមកអនុវត្តគម្រោង គឺខេត្តស្វាយរៀងក្នុងចំណោមរាជធានីខេត្តទាំង២៥ នៃប្រទេសកម្ពុជា និងជាខេត្តមួយមានទីតាំងស្ថិតនៅបណ្តោយផ្លូវជាតិលេខ១ ជាប់ព្រំដែនជាមួយប្រទេសវៀតណាម។

## ១.២. គោលបំណង

គោលបំណងសំខាន់ៗ នៃរបាយការណ៍លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ គឺផ្តល់ទិន្នន័យដែលជាតម្រូវការចាំបាច់សម្រាប់បម្រើសេចក្តីត្រូវការ៖

១. សម្រាប់ធ្វើគោលនយោបាយអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ

២. សម្រាប់ប្រើប្រាស់ក្នុងវិទ្យាស្ថានជាតិស្ថិតិ (NIS)

៣. សម្រាប់តម្រូវការអ្នកសិក្សាស្រាវជ្រាវ សាស្ត្រាចារ្យ និស្សិត.....

នៅក្នុងជំពូកទី២ នេះក៏បានបង្ហាញនូវទិន្នន័យដែលទាក់ទងទៅ នឹងព័ត៌មានប្រជាសាស្ត្រ សន្តិសុខសង្គម សេដ្ឋកិច្ច សង្គមកិច្ច សុខាភិបាល អប់រំ និងផ្នែកកសិកម្ម។ ការផ្សព្វផ្សាយរបាយការណ៍លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២០ នេះត្រូវបានធ្វើឡើងយ៉ាងលម្អិតលើព័ត៌មានដែលមានក្នុងកម្រងសំណួរនោះ ដោយមានការផ្សព្វផ្សាយ នៅក្នុងគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ (https៖//www.nis.gov.kh) ផងដែរ ។

## ១.៣. វិធីសាស្ត្រប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យ គឺធ្វើឡើងដោយមន្ត្រីនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ និងមានការចូលរួមពីមន្ត្រី នៃមន្ទីរផែនការខេត្តទាំងពីរផងដែរ ដោយបានប្រើប្រាស់កម្រងបញ្ជីសំណួរស្ថិតិថ្នាក់ក្រោមជាតិ ចុះសម្ភាសប្រធានភូមិដោយផ្ទាល់ គ្រប់ភូមិទាំងអស់ដែលមាននៅក្នុងខេត្តទាំងពីរ រយៈពេល១៥ថ្ងៃ គឺចាប់ពីថ្ងៃទី ០៥ ដល់ ២០ ខែមីនា ឆ្នាំ២០២០។ កាលបរិច្ឆេទយោងគឺរយៈពេល១២ខែកន្លងមក ដោយគិតចាប់ពី ខែ មីនា ឆ្នាំ២០២០ ដល់ ខែ មីនា ឆ្នាំ២០២១។

## ១.៤. ការកែច្នៃទិន្នន័យ

ទិន្នន័យនេះ គឺត្រូវបានធ្វើការកែច្នៃដោយដៃ និងប្រើប្រាស់កម្មវិធី CSPro សម្រាប់វាយបញ្ចូលទៅក្នុងកុំព្យូទ័រ។ កម្មវិធី CSPro, SPSS និង Microsoft Excel ក៏ត្រូវបានប្រើប្រាស់ផងដែរ សម្រាប់ធ្វើការវិភាគទិន្នន័យ បង្កើតជាតារាង និងសង់ជាក្រាហ្វិក មុននឹងឈានដល់ការបកស្រាយទិន្នន័យ និងវាយអត្ថបទចូលទៅក្នុងកម្មវិធី Microsoft Word ។ ការវាយបញ្ចូល និងវិភាគទិន្នន័យមានរយៈពេល០២ខែ គឺចាប់ពីថ្ងៃទី០១ ខែមេសា ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២១ បន្ទាប់ពីការចុះស្រង់ទិន្នន័យតាមមូលដ្ឋានរួចមក។

### ១.៤.១ ផែនទីចំនួនស្រុកក្នុងខេត្តស្វាយរៀង



## ១.៤.២ ផែនទីចំនួនខេត្តដែលបានប្រមូលទិន្នន័យ



# ជំពូកទី២
# វិភាគទិន្នន័យ

នៅក្នុងរបាយការណ៍នេះមានការវិភាគទិន្នន័យដែលទាក់ទងទៅនិងព័ត៌មាន ប្រជាសាស្ត្រ អប់រំ កសិកម្ម សេដ្ឋកិច្ច និងសង្គមកិច្ច។

## ២.១. ព័ត៌មានប្រជាសាស្ត្រ

### ២.១.១. ចំនួនប្រជាជន និងគ្រួសារ

ចំនួនគ្រួសារ និងប្រជាជននៅក្នុងខេត្តស្វាយរៀងមានចំនួនសរុប ១៥៨.២១៥ គ្រួសារ និងមានប្រជាជនសរុប ៦៥០.៥៩២ នាក់ (គិតត្រឹមថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ ) ។

***តារាងទី(១) ចំនួនប្រជាជន និងគ្រួសារ***

| **ចំនួនសរុប** | **ខេត្តស្វាយរៀង** |
|---|---|
| គ្រួសារ | 158,215 |
| ប្រជាជន | 650,592 |

តារាងទី(១) បង្ហាញឱ្យឃើញថា៖ **ខេត្តស្វាយរៀង** មានគ្រួសារសរុបចំនួន ១៥៨.២១៥ គ្រួសារ ដែលមានប្រជាជនសរុប ៦៥០.៥៩២នាក់។



រូបភាពទី(១) បានបង្ហាញថា៖ **ខេត្តស្វាយរៀង** មានមេគ្រួសារសរុប ១៥៨.២១៥ ក្នុងនោះមេគ្រួសារជាស្រ្តីមានចំនួន ១៦,៩% និងមាន ៣% មានកូនអាយុក្រោម៥ឆ្នាំក្នុងចំណោមគ្រួសារដែលមានស្រ្តីជាមេគ្រួសារទាំងនោះ។

## ២.១.២. ព័ត៌មានប្រជាជន

### ក. គ្រួសារតាមជនជាតិ



រូបភាពទី (២) ភាគរយគ្រួសារតាមជនជាតិ

រូបភាពទី(២) បានបង្ហាញថា៖ ក្នុងចំណោមគ្រួសារសរុបនៅខេត្តស្វាយរៀងមានភាគច្រើនបំផុតគឺមានគ្រួសារដែលជាជនជាតិខ្មែររស់នៅគឺ ៩៩,៨៩% ក្រៅពីគ្រួសារដែលជាជនជាតិខ្មែរ ក៏នៅមានគ្រួសារដែលជាជនជាតិផ្សេងតិចតួចរស់នៅផងដែរ គឺមានគ្រួសារជនជាតិវៀតណាម ០,០៩% និងគ្រួសារជនជាតិចិន ០,០២% តែប៉ុណ្ណោះ។

### ខ. ស្ថានភាពអាពាហ៍ពិពាហ៍របស់មេគ្រួសារ




រូបភាពទី(៣) បានបង្ហាញថា៖ ភាគរយស្ថានភាពអាពាហ៍ពិពាហ៍របស់មេគ្រួសារសរុបរួម ក្នុង **ខេត្តស្វាយរៀង** មានចំនួនសរុប ១៥៨.២១៥ ក្នុងនោះមានមេគ្រួសារដែលបានរៀបការរស់នៅជាមួយគ្នា ៨០,៨% ខុសឆ្ងាយពីមេគ្រួសារដែលរស់នៅផ្សេងគ្នាមានត្រឹមតែ ០,៤% ប៉ុណ្ណោះ។ ចំណែកមេគ្រួសារមេម៉ាយ/ពោះម៉ាយមាន ១៧,៣% ហើយមេគ្រួសារដែលរស់នៅជាមួយគ្នាដោយមិនបានរៀបការមាន ០,៩%។ ទន្ទឹមនោះក៏នៅមាន ០,៦% ទៀតដែលជាគ្រួសារដែលមានមេគ្រួសារមិនដែលរៀបការ។

## ២.១.៣. ការផ្លាស់ប្តូរទីលំនៅ

### ក. គ្រួសារធ្វើចំណាកស្រុកចេញ និងចូល



រូបភាពទី(៤) បានបង្ហាញថា៖ ស្ថានភាពការធ្វើអន្តោប្រវេសន៍របស់គ្រួសារនៅខេត្តស្វាយរៀងក្នុងចំណោមគ្រួសារសរុបចំនួន ១៥៨.២១៥គ្រួសារ មានគ្រួសារធ្វើចំណាកស្រុកចេញចំនួន ៣.៧៥៥គ្រួសារ និងគ្រួសារធ្វើចំណូលស្រុកចំនួន ១.៣១២គ្រួសារ។

### ខ. ចំនួនគ្រួសារធ្វើចំណាកស្រុកក្នុង និងក្រៅប្រទេស




រូបភាពទី(៥) បានបង្ហាញថា៖ ស្ថានភាពការធ្វើអន្តោប្រវេសន៍របស់ **ខេត្តស្វាយរៀង** ក្នុងចំណោមគ្រួសារសរុបចំនួន ១៥៨.២១៥ គ្រួសារ មានគ្រួសារដែលស្វែងរកការងារនៅក្នុងប្រទេសចំនួន ១៧.៤១៨ គ្រួសារ និងគ្រួសារដែលស្វែងរកការងារនៅក្រៅប្រទេសមានចំនួន ៣.៤២៩ គ្រួសារ ។

### គ. ពលករចំណាកស្រុកក្នុង និងក្រៅប្រទេស

***តារាងទី(២) ចំនួនអ្នកធ្វើចំណាកស្រុកក្នុង និងក្រៅប្រទេស***

| **ពលករចំណាកស្រុក** | **ស្វាយរៀង** |
|---|---|
| ក្នុងប្រទេស | 50,906 |
| ក្រៅប្រទេស | 6,811 |
| **សរុប** | **57,717** |

តារាងទី(២) បានបង្ហាញអំពី៖ ស្ថានភាពពលករចំណាកស្រុកក្នុងប្រទេស និងក្រៅប្រទេស រួមមាន៖ **ខេត្តស្វាយរៀង** មានគ្រួសារសរុបចំនួន ១៥៨.២១៥គ្រួសារ និងមានប្រជាជនសរុបចំនួន ៦៥០.៥៩២នាក់ នៅចំណោមប្រជាជនសរុបទាំងនោះគឺមាន ៥៧.៧១៧នាក់ ជាពលករ ដែលក្នុងនោះមានពលករធ្វើការងារនៅក្នុងប្រទេសចំនួន ៥០.៩០៦នាក់ និងពលករធ្វើការងារនៅក្រៅប្រទេសចំនួន ៦.៨១១នាក់។

### ឃ. ពលករស្វែងរកការងារក្នុង និងក្រៅប្រទេសបែងចែកតាមភេទ

#### ១. ក្នុងប្រទេស




រូបភាពទី(៧) បានបង្ហាញថា៖ ស្ថានភាពពលករចំណាកស្រុកដើម្បីស្វែងរកការងារនៅក្នុងប្រទេស របស់**ខេត្តស្វាយរៀង** ដែលមានភាគរយជាពលការីនីស្មើនឹង ៥៤,២% ក្នុងចំណោមពលករសរុប ៥០.៩០៦នាក់។

### ២. ក្រៅប្រទេស




រូបភាពទី(៧) បានបង្ហាញថា៖ ស្ថានភាពពលករចំណាកស្រុកដើម្បីស្វែងរកការងារនៅក្រៅប្រទេសរបស់ **ខេត្តស្វាយរៀង** ពលករដែលជាបុរសមានភាគរយចំនួន ៦២,២% ច្រើនជាងពលការីនីស្មើនឹង ៣៧,៨% ក្នុងចំណោមពលករសរុប ៦.៨១១នាក់។

## ២.១.៤. លំនៅដ្ឋាន

### ក. ប្រភេទនៃដំបូលផ្ទះតាមគ្រួសារ

***តារាងទី(៣) ប្រភេទនៃដំបូលផ្ទះ***

| ប្រភេទនៃដំបូលផ្ទះ | ស្វាយរៀង | |
|---|---|---|
| | ចំនួន | % |
| បេតុង | 6,341 | 4.5 |
| ក្បឿង | 38,669 | 27.7 |
| ស័ង្កសី / ហ្វីប្រូ | 91,274 | 65.4 |
| ប្រក់ស្លឹក | 647 | 0.5 |
| ផ្សេងទៀត | 2,605 | 1.9 |
| **សរុប** | **139,536** | **100 %** |

តារាងទី(៣) បានបង្ហាញពីភាគរយនៃដំបូលផ្ទះរបស់ប្រជាពលរដ្ឋក្នុង **ខេត្តស្វាយរៀង** មានខ្នងផ្ទះសរុប ១៣៩.៦៣៦ខ្នងផ្ទះ ក្នុងនោះផ្ទះដំបូលប្រក់អំពីស័ង្កសី/ហ្វីប្រូ មានចំនួន ៩១.២៧៤ខ្នងផ្ទះ ស្មើនឹង ៦៥,៤% ដែលជាភាគរយខ្ពស់ជាងគេ រីឯផ្ទះដែលមានដំបូលប្រក់ស្លឹកមានត្រឹមតែ ៦៤៧ ខ្នងផ្ទះ ស្មើនឹង ០,៥% ដែលជាភាគរយទាបជាងគេបំផុតក្នុងចំណោមផ្ទះប្រក់ដំបូលផ្សេងទៀត។ ទន្ទឹមនឹងនោះក៏នៅមានផ្ទះប្រក់ដំបូលក្បឿង ៣៨.៦៦៩ខ្នងផ្ទះ ស្មើនឹង ២៧,៧% ដំបូលបេតុង ៦.៣៤១ខ្នងផ្ទះ ស្មើនឹង ៤,៥% និងផ្ទះប្រក់ដំបូលផ្សេងទៀត ២.៦០៥ខ្នងផ្ទះ ដែលស្មើនឹង ១,៩%។

## ខ. មូលដ្ឋានសម្ភារៈបរិក្ខាដែលមានតាមខ្នងផ្ទះ



រូបភាពទី(៨) ភាគរយនៃខ្នងផ្ទះចែកតាមប្រភេទសម្ភារៈបរិក្ខាដែលមាននៅខេត្តស្វាយរៀង

រូបភាពទី(៨) បានបង្ហាញថានៅខេត្តស្វាយរៀងក្នុងចំណោមខ្នងផ្ទះសរុបចំនួន ១៣៩.៦៣៦ ផ្ទះដែលមានអគ្គិសនីប្រើប្រាស់ចំនួន ៧៦,៥% ស្មើនឹង (១០៦.៧៧៨ខ្នងផ្ទះ) ចំណែកឯផ្ទះដែលមានទូរទស្សន៍ប្រើប្រាស់គឺចំនួន ៨៧,៤% (១២១.៩៨៤ខ្នងផ្ទះ) ចំពោះផ្ទះដែលមានកំព្យូទ័រប្រើប្រាស់មានចំនួន ២,៨% (៣.៨៨៦ខ្នងផ្ទះ) ប៉ុណ្ណោះ រីឯផ្ទះដែលមានអ៊ីនធឺណេតប្រើប្រាស់មានចំនួន ៣៨,៣% ស្មើនឹង (៥៣.៥០៧ខ្នងផ្ទះ) ចុងក្រោយគឺមានចំនួនច្រើនជាងគេសម្រាប់ផ្ទះដែលមានទូរស័ព្ទប្រើប្រាស់មានរហូតដល់ ៩៨,២%ស្មើនឹង (១៣៧.០១០ខ្នងផ្ទះ) ។

## គ. ការប្រើប្រាស់អគ្គិសនីតាមដំបូលផ្ទះ




រូបភាពទី(៩) បានបង្ហាញថា គ្រប់ខ្នងផ្ទះទាំងអស់នៃប្រភេទដំបូលជាបេតុងគឺមានអគ្គិសនីប្រើប្រាស់ ១០០% (៦.៣៤១ខ្នងផ្ទះ) ចំណែកឯខ្នងផ្ទះដែលមានប្រភេទដំបូលប្រក់ស្លឹក/ផ្សេងទៀតគឺមានអគ្គិសនីប្រើប្រាស់តែ ៧១,៧% (២.៣៣៤ខ្នងផ្ទះ) ចំនួនតិចជាងគេ បន្ទាប់មកផ្ទះដំបូលក្បឿងមានអគ្គីសនីប្រើប្រាស់ ៧៤,៧% (២.៨៨៧ខ្នងផ្ទះ) និងផ្ទះដំបូលស័ង្កសី/ហ្វីប្រូមាន ៧៥,៤% (៦៨.៨៣០ខ្នងផ្ទះ) ។ សូមបញ្ជាក់មានអគ្គីសនីប្រើប្រាស់គឺមិនរាប់បញ្ចូលការប្រើប្រាស់អាគុយ ផ្ទាំងសូឡាឡើយគឺសំដៅទៅលើអគ្គីសនីមានបណ្តាញត្រឹមត្រូវពីរដ្ឋ ក្រុមហ៊ុន ឬអ្នកម៉ៅការ។

## ឃ. ការប្រើប្រាស់ទូរទស្សន៍តាមដំបូលផ្ទះ



រូបភាពទី(១០)បានបង្ហាញថា គ្រប់ខ្នងផ្ទះទាំងអស់នៃប្រភេទដំបូលជាបេតុងគឺមានទូរទស្សន៍ប្រើប្រាស់ទាំងអស់ ១០០% (៦.៣៤១ខ្នងផ្ទះ) ចំណែកឯខ្នងផ្ទះដែលមានប្រភេទដំបូលប្រក់ស្លឹក/ផ្សេងទៀតគឺមានទូរទស្សន៍ប្រើប្រាស់តែ ៨២,១% (២.៦៧១ខ្នងផ្ទះ) គឺមានចំនួនតិចជាងគេបើប្រៀបធៀបទៅប្រភេទដំបូលផ្សេងទៀត បន្ទាប់មកផ្ទះដំបូលក្បឿងមានទូរទស្សន៍ប្រើប្រាស់ ស្ទើរតែទាំងអស់ ៩៤,៥% (៣៦.៥៣៤ខ្នងផ្ទះ)និងផ្ទះដំបូលស័ង្កសី/ហ្វីប្រូមាន ៨២,៥%(៧៥.៣៤៤ខ្នងផ្ទះ)។

## ង. ការប្រើប្រាស់កុំព្យូទ័រតាមដំបូលផ្ទះ




រូបភាពទី(១១) បានបង្ហាញថា គ្រប់ខ្នងផ្ទះទាំងអស់នៃប្រភេទដំបូលជាបេតុង គឺមានអាត្រាកំព្យូទ័រប្រើប្រាស់ច្រើនជាងគេ ១០,១% (៦៣៨ខ្នងផ្ទះ) ចំណែកឯខ្នងផ្ទះដែលមានប្រភេទដំបូលប្រក់ស្លឹក/ផ្សេងទៀតគឺមានអាត្រាកំព្យូទ័រប្រើប្រាស់តិចជាងគេគឺ ២,១% (៦៨ខ្នងផ្ទះ) គឺមានចំនួនទាបជាងគេបើប្រៀបធៀបទៅប្រភេទដំបូលផ្សេងទៀត ចំណែកឯផ្ទះដំបូលក្បឿងមានអាត្រាកំព្យូទ័រប្រើប្រាស់ស្ទើរតែទាំងអស់ ៣,១% (១.២០៥ខ្នងផ្ទះ) និងផ្ទះដំបូលស័ង្កសី/ហ្វីប្រូមានអាត្រាកំព្យូទ័រប្រើប្រាស់ ២,២% (១.៩៧៥ខ្នងផ្ទះ)។

### ច. ការប្រើប្រាស់អ៊ីនធើណេតតាមដំបូលផ្ទះ



រូបភាពទី(១២)៖ ចំនួនខ្នងផ្ទះដែលមានអ៊ីនធើណេតប្រើប្រាស់ចែកតាមប្រភេទនៃដំបូលផ្ទះ

រូបភាពទី(១២) បានបង្ហាញថា គ្រប់ខ្នងផ្ទះដំបូលស័ង្កសី/ហ្វីប្រូ មានអាត្រាប្រើប្រាស់អ៊ីនធើណេតច្រើនជាងគេ ៤៥,៣% (៤១.៣២៧ខ្នងផ្ទះ) បន្ទាប់មកប្រភេទដំបូលជាបេតុងគឺមានអាត្រាប្រើប្រាស់អ៊ីនធើណេត ៣៤,២% (២.១៦៩ខ្នងផ្ទះ) ចំណែកឯខ្នងផ្ទះដែលមានប្រភេទដំបូលប្រក់ស្លឹក/ផ្សេងទៀតគឺមានអាត្រាប្រើប្រាស់អ៊ីនធើណេតតិចជាងគេគឺ ២៩,២% (៩៥១ខ្នងផ្ទះ) ។

### ឆ. ការប្រើប្រាស់ទូរស័ព្ទដៃតាមដំបូលផ្ទះ



រូបភាពទី (១៣)៖ ចំនួនខ្នងផ្ទះដែលមានទូរស័ព្ទប្រើប្រាស់ចែកតាមប្រភេទនៃដំបូលផ្ទះ

រូបភាពទី(១៣) បានបង្ហាញថា៖ គ្រប់ខ្នងផ្ទះទាំងអស់នៃប្រភេទដំបូលជាបេតុង ដំបូលប្រក់អំពីក្បឿង និងដំបូលប្រក់អំពីស័ង្កសី/ហ្វីប្រូ គឺមានទូរស័ព្ទប្រើប្រាស់ទាំងអស់គឺ ១០០% លើកលែងតែខ្នងផ្ទះដំបូលប្រក់អំពីស្លឹកមានទូរស័ព្ទប្រើប្រាស់ត្រឹមតែ ២២,៣% (៧២៦ខ្នងផ្ទះ) ប៉ុណ្ណោះ។

## ២.១.៥. សម្ភារ ឬបរិក្ខារដឹកជញ្ជូន

***តារាងទី(៤) ប្រភេទបរិក្ខារតាមប្រភេទ***

| ប្រភេទបរិក្ខារ | ស្វាយរៀង | |
|---|---|---|
| | ចំនួន | ភាគរយ |
| ឧបករណ៍កសិកម្មនិងគ្រឿងម៉ាស៊ីនម៉ាស៊ីនភ្ជួររាស់ | 12,933 | 8.40 |
| ម៉ាស៊ីនប្រមូលផល | 958 | 0.62 |
| ឧបករណ៍កសិកម្មផ្សេងទៀត | 1,006 | 0.65 |
| រថយន្តដឹកអ្នកដំណើរ(តាក់ស៊ីនិង១២កៅអី) | 955 | 0.62 |
| រថយន្តដឹកទំនិញ | 939 | 0.61 |
| រថយន្តក្រុង | 136 | 0.09 |
| រថយន្តលក្ខណៈគ្រួសារ | 7,909 | 5.14 |
| ម៉ូតូ | 122,281 | 79.44 |
| រទេះអូសដោយដៃ | 3,963 | 2.57 |
| ម៉ូតូកង់បី | 2,381 | 1.55 |
| រទេះគោនិងសេះ | 163 | 0.11 |
| ទូក | 204 | 0.13 |
| ទូកដឹកអ្នកដំណើរ | 31 | 0.02 |
| ទូកនេសាទ | 32 | 0.02 |
| ទូកផ្សេងៗ | 36 | 0.02 |
| **សរុប** | **153,927** | **100.00** |

តារាងទី(៤)បានបង្ហាញពីចំនួននិងភាគរយនៃប្រភេទបរិក្ខារដែលមាននៅក្នុងខេត្តស្វាយរៀង ក្នុងចំណោមបរិក្ខាសម្ភារៈទាំងអស់ឃើញថាចំនួនម៉ូតូមានចំនួនភាគរយច្រើនជាងគេគឺ ៧៩,៤៤% (១២២.២៨១គ្រឿង) ចំណែកចំនួនភាគរយនៃឧបករណ៍កសិកម្មនិងគ្រឿងម៉ាស៊ីនម៉ាស៊ីនភ្ជួររាស់ឈរនៅលំដាប់លេខពីរគឺ ៨,៤០% (១២.៩៣៣គ្រឿង) និងបន្ទាប់មកចំនួនរថយន្តលក្ខណៈគ្រួសារ

មានភាគរយ ៥,១៤% (៧.៩០៩គ្រឿង)។ ក្រៅពីនោះមានបរិក្ខាសម្ភារៈសំខាន់ៗដូចជាម៉ាស៊ីនប្រមូលផលមានចំនួន ៩៥៨គ្រឿង រថយន្តដឹកអ្នកដំណើរចំនួន ៩៥៥គ្រឿង និងរថយន្តដឹកទំនិញចំនួន ៩៣៩គ្រឿង។

## ២.២. អត្រាកំណើត និងមរណភាព

### ២.២.១. អត្រាកំណើត

#### ក. ភេទនៃទារកកើត*ក្នុងរយៈពេល១២ខែកន្លងមក*




រូបភាពទី(១៤) បានបង្ហាញថា ទារកដែលបានកើតក្នុងរយៈពេល១២ខែកន្លងមកនៅខេត្តស្វាយរៀងមានចំនួនសរុប ៨.០០០នាក់ក្នុងនោះទារកភេទស្រីមានភាគរយចំនួន ៥២,១៩% (៤១៧៥នាក់) ច្រើនជាងទារកមានភេទប្រុសមានភាគរយ ៤៧,៨១% (៣៨២៥នាក់)។

### ក. ទីកំណើតទារកកើតក្នុងរយៈពេល១២ខែកន្លងមក




រូបភាពទី(១៥) បានបង្ហាញថា នៅខេត្តស្វាយរៀង ក្នុងចំណោមទារកដែលបានកើត ៨.០០០ នាក់ មាន ៩៨,២% (៧.៨៥៦នាក់) បានកើតដោយមន្ទីរពេទ្យរដ្ឋ និងមានតែ ០,៧% (៥៦នាក់) ដែលមានលទ្ធភាពកើតដោយមន្ទីរពេទ្យឯកជន ហើយគួរឲ្យកត់សម្គាល់មានទារកចំនួន ១,១% (៨៨ នាក់) បានកើតដោយឆ្មបបុរាណនិងកើតដោយមធ្យោបាយផ្សេងៗទៀត។

## ២.២.២. មរណភាព

### ក. ភាគរយនៃស្លាប់បែងចែកតាមមូលហេតុនៃការស្លាប់



រូបភាពទី(១៦) បានបង្ហាញថា នៅក្នុងចំណោមអ្នកស្លាប់នៅខេត្តស្វាយរៀងគឺអ្នកស្លាប់ដោយមូលហេតុជំងឺមានគាគរយច្រើនជាងគេរហូតដល់ទៅ ៧០,២% (២.៧៤២នាក់) ចំណែកការស្លាប់ដោយគ្រោះថ្នាក់ចរាចរក៏មានចំនួនគួរឲ្យកត់សម្គាល់ផងដែរមាន ៤% (១៥៧នាក់) ក្នុងរយៈពេល ១២ខែកន្លងមក បន្ទាប់មកការស្លាប់ដោយលង់ទឹកមាន ១,២% (៤៧នាក់) និងការស្លាប់ដោយពស់ចឹកមានភាគរយតិចជាងគេមានតែ ០,១% បន្ទាប់ពីរស្លាប់ដោយឃាតកម្មមាន ០,៣% (១២នាក់)។

## ខ. ចំនួនអ្នស្លាប់បែងចែកតាមភេទមូលហេតុនៃការស្លាប់



រូបភាពទី(១៧) ចំនួនអ្នស្លាប់បែងចែកតាមភេទមូលហេតុនៃការស្លាប់

រូបភាពទី(១៧) បានបង្ហាញថា នៅក្នុងខេត្តស្វាយរៀងការស្លាប់ដោយជំងឺគឺស្ត្រីស្លាប់ច្រើនជាងប្រុស (ស្ត្រីមាន១,៤៤៩នាក់ ប្រុសមាន១,២៩៣នាក់) ផ្ទុយពីការស្លាប់ដោយសារគ្រោះថ្នាក់ចរាចរ ដោយលង់ទឹក ពស់ចឹក និងឃាតកម្ម ប្រុសមានចំនួនច្រើនជាងស្រី នៅក្នុងចំណោមអ្នកស្លាប់ចំពោះការស្លាប់ដោយមូលហេតុផ្សេងៗក៏ស្រីមានចំនួនច្រើនជាងប្រុសដែរ។

### គ. ការស្លាប់បែងចែកតាមក្រុមអាយុ និងភេទ




រូបភាពទី(១៨)បានបង្ហាញថាបើយើងពិនិត្យទៅលើក្រុមអាយុនិងភេទរបស់អ្នកស្លាប់នៅខេត្តស្វាយរៀងបានបង្ហាញថា ក្រុមអាយុពី១៨ ដល់ ៦៤ឆ្នាំ គឺមានចំនួនច្រើនជាងគេ ហើយអ្នកស្លាប់ភេទប្រុសមានមានចំនួនច្រើនជាងពាក់កណ្តាលនៃចំនួនអ្នកស្លាប់ភេទស្រ្តី អ្នកស្លាប់ស្ថិតនៅចន្លោះក្រុមអាយុ ៦៥ឆ្នាំឡើងឈរនៅលំដាប់ទីពីរ បន្ទាប់មកក្រុមអាយុ ៥ ដល់ ១៧ឆ្នាំ និងចំនួនតិចជាងគេស្ថិតក្នុងក្រុមអាយុ 0 ទៅ ៥ឆ្នាំ។

## ២.៣. ពិការភាព និងបុគ្គលគ្មានអ្នកមើលថែ

***តារាងទី(៥) ពិការភាពនៃបុគ្គល***

| ខេត្តស្វាយរៀង | សរុប | ប្រុស | ស្រី |
|---|---|---|---|
| សរុប | 3747 | 1946 | 1801 |
| បុគ្គលដែលរងគ្រោះដោយសារគ្រាប់មីន | 166 | 142 | 24 |
| មនុស្សចាស់ដែលគ្មានអ្នកមើលថែ ឬគ្រួសារផ្គត់ផ្គង់ | 445 | 104 | 341 |
| អនីតិជនដែលពិការ(អាយុក្រោម១៨ឆ្នាំ) | 758 | 411 | 347 |
| បុគ្គលពិការដែលមានប្រភពចំណូល | 896 | 543 | 353 |
| បុគ្គលពិការដែលគ្មានចំណូល | 1482 | 746 | 736 |

តារាងទី(៥)បានបង្ហាញថាបុគ្គលដែលរងគ្រោះដោយគ្រាប់មីនមានចំនួន ១៦៦នាក់ ក្នុងនោះ បុរសមានចំនួនច្រើនលើសលុបចំនួន ១៤២នាក់ ជាងស្ត្រីមានតែ ២៤នាក់ ចំណែកឯចំនួនមនុស្ស ចាស់ដែលគ្មានអ្នកមើលថែឬគ្រួសារផ្គត់ផ្គង់មានចំនួន ៤៤៥នាក់ ក្នុងនោះស្ត្រីមានចំនួន ៣៤១នាក់ ច្រើនជាងពាក់កណ្តាលមនុស្សចាស់ដែលមានភេទជាបុរសមានតែ ១០៤នាក់ប៉ុណ្ណោះ។

### គ. ភាគរយបុគ្គលពិការភាពចែកតាមភេទ




រូបភាពទី(១៩)បានបង្ហាញថា ចំនួនបុគ្គលពិការនៅខេត្តស្វាយរៀងមានចំនួនសរុប ៣.១៣៦ នាក់ ក្នុងនោះបុគ្គលពិការភេទបុរសមានចំនួន ៥៤,២% (១៧០០នាក់) ច្រើនជាងស្ត្រីមានភាគរយ ចំនួន ៤៥,៨% (១.៤៣៦នាក់)។

### ខ. ចំនួនបុគ្គលពិការភាពដែលមានប្រភពចំណូល និងគ្មានប្រភពចំណូល




រូបភាពទី(២០) បានបង្ហាញថា ក្នុងចំណោមបុគ្គលពិការនៅក្នុងខេត្តស្វាយរៀងមានអ្នកពិការអាយុក្រោម ១៨ឆ្នាំចំនួន ៧៥៨នាក់ ក្នុងនោះភេទប្រុសមានចំនួន ៤១១នាក់ ច្រើនជាងស្រីមានចំនួន ៣៧៤នាក់ ហើយបុគ្គលពិការដែលគ្មានប្រភពចំណូលមានចំនួន ១៤៨២នាក់ច្រើនជាងបុគ្គលពិការដែលមានប្រភពចំណូលគឺមានចំនួន ៩៩៦នាក់ ក្នុងនោះភេទប្រុសមានប្រភពចំណូលច្រើនជាងជិតពាក់កណ្តាលនៃបុគ្គលពិការមានប្រភពចំណូលភេទស្រី។

## ២.៤. ការប្រើប្រាស់ទឹក និងអនាម័យ

### ក. ការប្រើប្រាស់ទឹកស្អាតសម្រាប់បរិភោគ



រូបភាពទី(២១) បានបង្ហាញថា ក្នុងចំណោមគ្រួសារសរុបដែលរស់នៅក្នុងខេត្តស្វាយរៀង ភាគរយនៃគ្រួសារដែលមានទឹកស្អាតប្រើប្រាស់សម្រាប់បរិភោគមានតែ ២១,២% ប៉ុណ្ណោះ ចំណែកគ្រួសារដែលគ្មានទឹកស្អាតប្រើប្រាស់សម្រាប់បរិភោគមានរហូតដល់ទៅ ៧៨,៨%។ **ចំណាំ៖** ទឹកស្អាតប្រើប្រាស់សម្រាប់បរិភោគសំដៅទៅលើទឹកដែលមានការត្រួតពិនិត្យ និងប្រព័ន្ធទុយោតភ្ជាប់ដោយរដ្ឋ ឬឯកជនតែប៉ុណ្ណោះ។

### ខ. ប្រភពនៃការប្រើប្រាស់ទឹកសម្រាប់បរិភោគ




រូបភាពទី(២២)បានបង្ហាញថា គ្រួសាររស់នៅក្នុងខេត្តស្វាយរៀងគឺបានប្រើប្រាស់ទឹកអណ្តូងច្រើនជាងគេចំនួន ១២៣.១៧៩គ្រួសារ បន្ទាប់មកគ្រួសារដែលមានទឹកស្អាតប្រើប្រាស់ចំនួន ៣៣.៦១៣គ្រួសារ ហើយគ្រួសារប្រើប្រាស់ទឹក ស្រះ/បឹង/ស្ទឹង/ទន្លេ មានចំនួន៧៥៧គ្រួសារ និងការប្រើប្រាស់ទឹកភ្លៀង សម្រាប់បរិភោគមានចំនួនតិចជាងគេគឺ ៦៦៦គ្រួសារប៉ុណ្ណោះ។

## គ. បង្គន់អនាម័យ




រូបភាពទី(២៣)បានបង្ហាញនៅក្នុងខេត្តស្វាយរៀងគ្រួសារភាគច្រើនមានបង្គន់អនាម័យផ្ទាល់ខ្លួនប្រើប្រាស់គឺមានភាគរយស្មើនឹង ៨៣,៧% ប៉ុន្តែក៏មានគ្រួសារមួយចំនួនរស់នៅតាមជនបទមិនទាន់មានបង្គន់អនាម័យផ្ទាល់ខ្លួនប្រើប្រាស់នៅឡើយគឺមានភាគរយ ១៦,៣% បើប្រៀបធៀបទៅនឹងគ្រួសារទាំងអស់នៅទូរទាំងខេត្ត។

## ឃ. គ្រួសារគ្មានផ្ទះសម្បែង



រូបភាពទី(២៤) បានបង្ហាញថានៅក្នុងខេត្តស្វាយរៀងនៅមានគ្រួសារមួយចំនួនតូចមិនមានទីលំនៅច្បាស់លាស់ និងរស់នៅលើដីសាធារណៈគឺមានចំនួន ០,៨% (១.២៣៩គ្រួសារ) ហើយស្ទើរតែទាំងអស់នៃគ្រួសារក្នុងខេត្តមានផ្ទះទីតាំងស្របច្បាប់ត្រឹមត្រូវក្នុងការរស់នៅរបស់ខ្លួនគឺ ៩៩,២% (១៥៦.៩៧៦គ្រួសារ)។




រូបភាពទី(២៥)បានបង្ហាញថា នៅក្នុងចំណោមគ្រួសារមិនមានទីលំនៅច្បាស់លាស់ និងរស់នៅលើដីសាធារណៈនៃខេត្តស្វាយរៀងនៅមានគ្រួសារដែលគ្មានផ្ទះសម្បែងមានចំនួន ៦៣៦គ្រួសារ ច្រើនជាងគ្រួសារដែលរស់នៅលើដីសាធារណៈមានចំនួន ៦០៣គ្រួសារ។

## ២.៥. បរិស្ថាន និងគ្រោះធម្មជាតិ

### ក. គ្រោះធម្មជាតិ

រូបភាពទី(២៦) ចំនួនគ្រួសារ និងផ្ទៃដីដែលរងផលប៉ះពាល់ពីគ្រោះធម្មជាតិ




រូបភាពទី(២៦)បានបង្ហាញថា នៅក្នុងខេត្តស្វាយរៀងមានគ្រួសារ និងផ្ទៃដីមួយចំនួនបានទទួលរងនូវផលប៉ះពាល់ពីគ្រោះធម្មជាតិដូចជា រងគ្រោះរាំងស្ងួត គ្រោះទឹកជំនន់ និងទទួលរងនូវខ្យល់ព្យុះឬខ្យល់កន្ត្រាក់ ក្នុងនោះការរងនៃភាពរាំងស្ងួតមានចំនួនច្រើនជាងគេគឺ ១.៧៥៥គ្រួសារ ស្មើនឹងផ្ទៃដី ១.៥៧២ហិកតា បន្ទាប់មកការរងនូវគ្រោះដោយទឹកជំនន់មានចំនួន ១.២៣៣គ្រួសារ ស្មើនឹងផ្ទៃដី ៨៨៨ហិកតា និងគ្រួសាររងផលប៉ះពាល់ដោយខ្យល់ព្យុះឬខ្យល់កន្ត្រាក់មានចំនួនតិចជាងគេគឺ ៧០១គ្រួសារ ខូចខាតលើផ្ទៃដី ៤២១ហិកតា ។

## ខ.ផ្ទៃដីចោលសំរាម ព្រៃឈើ និងការដាំកូនឈើ




រូបភាពទី(២៧) បានបង្ហាញថានៅខេត្តស្វាយរៀងមានទីតាំងចោលសំរាមតិចតួចគឺមានតែ ០,២៥ហិកតាប៉ុណ្ណោះ ហើយផ្ទៃដីគ្របដណ្តប់ព្រៃឈើក៍មានចំនួនតិចផងដែរគឺ ៧១៨ហិកតា ប៉ុន្តែបានមានការដាំកូនឈើនៅលើផ្ទៃដី ៧៨២ហិកតា។

## គ. គ្រួសារប្រើប្រាស់ប្រភពសម្រាប់ចំអិនអាហារ




រូបភាពទី(២៧) បានបង្ហាញថានៅខេត្តស្វាយរៀងមានគ្រួសារចំនួន ៣៣% បានប្រើប្រាស់អុស/ធ្យូងក្នុងការចំអិនអាហារ ហើយបានប្រើប្រាស់ប្រភពផ្សេងទៀតមានភាគរយ ៦៧%។

## ២.៧. សន្តិសុខសង្គម និងសេដ្ឋកិច្ច

### ២.៧.១. អសន្តិសុខសង្គម

បញ្ហាអសន្តិសុខសង្គមសំដៅលើការលួច ឆក់ ប្លន់ ចាប់ជម្រិត ឧក្រិដ្ឋកម្ម ប្រើប្រាស់គ្រឿងញៀន និងជម្លោះដីធ្លីនៅក្នុងមូលដ្ឋានជាដើម។ ចំពោះករណីទាំងអស់នោះ ទោះបីជាមានចំនួនកើតឡើងច្រើនយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាល និងអាជ្ញាធរខេត្តស្វាយរៀងខិតខំដោះស្រាយបានមួយចំនួនធំដែរ ដូចមានតួលេខបានបញ្ជាក់ដូចខាងក្រោមនេះ ៖

#### ក. ករណីអសន្តិសុខសង្គមដែលកើតឡើងឃាតកម្ម

រូបភាពទី (២៩) ចំនួនករណីកើតឡើងបែងចែកតាមប្រភេទសន្តិសុខសង្គម




រូបភាពទី(២៩) បានបង្ហាញថា នៅខេត្តស្វាយរៀងមានករណីអសន្តិសុខសង្គមកើតឡើងច្រើនជាងគេគឺ ប្រជាពលរដ្ឋទាស់ទែងគ្នាមានចំនួន ៧១៦ករណី បញ្ហាជម្លោះដីធ្លីឈរនៅលំដាប់ទី២គឺចំនួន ៧០៦ករណី ហើយការលួចមានចំនួន ៦៣ករណី បន្ទាប់មកក៏មានអំពើឃាតកម្ម/ប្លន់/ចាប់ជម្រិតចំនួន ១៧ករណី ផងដែរ និងចុងក្រោយគេគឺបញ្ហាឧក្រិដកម្មមានតែចំនួន ០៣ករណីប៉ុណ្ណោះ។

## ខ. ចំនួនភាគរយនៃករណីអសន្តិសុខសង្គមដែលបានដោះស្រាយ




រូបភាពទី(៣០) បានបង្ហាញថា ក្នុងចំណោមករណីអសន្តិសុខដែលកើតមាននៅក្នុងខេត្តស្វាយរៀងគឺ ត្រូវបានដោះស្រាយដោយអាជ្ញាធរបានច្រើនករណីផងដែរ ក្នុងនោះករណីប្រជាពលរដ្ឋឈ្លោះទាស់ទែងគ្នាគឺបានដោះស្រាយស្ទើតែទាំងអស់គឺមានភាគរយ ៩៦,៩% គឺមានភាគរយតែ ៣,១% ប៉ុណ្ណោះដែលមិនទាន់បានដោះស្រាយ បន្ទាប់មកបញ្ហាជម្លោះដីធ្លីក៏ដោះស្រាយបានច្រើនគួរឲ្យកត់សម្គាល់ផងដែរគឺមានភាគរយរហូតដល់ទៅ ៩៤,៩% បន្ទាប់មកគឺករណីលួច ឈរនៅលំដាប់ទី៣គឺដោះស្រាយបាន ៨៥,៧% គឺនៅមានភាគរយតែ ១៤,៣% ដែលមិនទាន់បានដោះស្រាយ ចំណែកឯករណីឧក្រិដកម្មវិញគឺមានចំនួនតិចតួចណាស់ហើយក៏បានដោះខ្លះដែរគឺមានភាគរយ ៣៣,៣% ចុងក្រោយគេគឺ ករណីរឃាតកម្ម/ប្លន់/ចាប់ជម្រិត គឺបានដោះស្រាយមានចំនួនភាគរយតែ ១៧,៦% ប៉ុណ្ណោះ គឺនៅសល់ភាគរយរហូតដល់ ៨២,៤% ដែលមិនទាន់ត្រូវបានដោះស្រាយ។

## គ. អំពើហិង្សាក្នុងគ្រួសារ និងគ្រឿងញៀន




រូបភាពទី(៣១) ក្នុងចំណោមគ្រួសារសរុប (១៥៨,២១៥គ្រួសារ) ដែលរស់នៅ**ខេត្តស្វាយរៀង** មានគ្រួសារចំនួន ៩២១គ្រួសារដែលបានទទួលរងនូវអំពើហឹង្សាក្នុងគ្រួសារ និងគ្រឿងញៀន ក្នុងនោះគ្រួសារចំនួន ៤៦៧គ្រួសារ បានជួបអំពើហិង្សាក្នុងគ្រួសារ និង ៤៥៤គ្រួសារប្រើប្រាស់គ្រឿងញៀន។

## ឃ. ស្ត្រីរងគ្រោះដោយការចាប់រំលោភ និងជួញដូរ



រូបភាពទី(៣២) បង្ហាញថា ក្នុងចំណោមប្រជាជនជាស្ត្រីទាំងអស់ដែលរស់នៅខេត្តស្វាយរៀងគឺមានករណីស្ត្រីរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទ និងការជួញដូរចំនួន ១៣នាក់ ក្នុងនោះភាគច្រើនបំផុតគឺរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទរហូតដល់ទៅ ១២នាក់ ចំណែកឯការជួញដូរផ្លូវភេទមានតែ ១នាក់ ប៉ុណ្ណោះ។

### ឃ. ស្ត្រីរងគ្រោះដោយការចាប់រំលោភ បែងចែកជាក្រុមអាយុ




រូបភាពទី(៣៣) បង្ហាញថា ក្នុងចំណោមស្ត្រីដែលទទួលរងការចាប់រំលោភនៅខេត្តស្វាយរៀងគឺភាគច្រើនជាស្ត្រីដែលមានអាយុតិចជាង១៨ឆ្នាំ គឺមាន ៩នាក់ ក្នុងចំណោម ១២នាក់ ចំណែកស្ត្រីរងគ្រោះដោយការចាប់រំលោភអាយុលើសពី១៨ឆ្នាំ មានតែ ៣នាក់ប៉ុណ្ណោះក្នុងចំណោម ១២នាក់នោះ។

## ២.៧.២. សេដ្ឋកិច្ចគ្រួសារ

នៅក្នុងប្រទេសកម្ពុជាយើងមានសកម្មភាពអាជីវកម្មជាច្រើនដែលប្រជាជនធ្វើសកម្មភាពដើម្បីរកស៊ីចិញ្ចឹមជីវិតដោយមិនរាប់ចូលសកម្មភាពកសិកម្ម។ ចំណោមសកម្មភាពអាជីវកម្មទាំងអស់នោះយើងបានជ្រើសរើសសកម្មភាពអាជីវកម្មសំខាន់ៗចំនួន១៨អាជីវកម្មដើម្បីយកមកបង្ហាញសម្រាប់ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ។

## ក. គ្រួសារដែលមានសកម្មភាពអជីវកម្មនៅខេត្តស្វាយរៀង

រូបភាពទី(៣៤) ភាគរយគ្រួសារដែលប្រកបអាជីវកម្ម




រូបភាពទី(៣៤) បង្ហាញថា ក្នុងចំណោមចំនួនគ្រួសារសរុបនៅក្នុងខេត្តស្វាយរៀងគឺមានគ្រួសារចំនួន ៨% ដែលបានប្រកបរបរអាជីវកម្ម និងមាន ៩២% ដែលមិនបានចូលរួមសកម្មភាពអាជីវកម្ម។

## ខ. សកម្មភាពអជីវកម្មចម្បងរបស់គ្រួសារមានច្រើនជាង១០% ប្រៀបធៀបសរុបក្នុងខេត្ត

រូបភាពទី(៣៥) ចំនួនគ្រួសារដែលប្រកបអាជីវកម្មចម្បង



រូបភាពទី(៣៥) បង្ហាញថា នៅក្នុងខេត្តស្វាយរៀងមានគ្រួសារប្រកបរបរអាជីវកម្មជាតូបលក់សាំងតូចៗច្រើនជាងគេមានចំនួន៣១៣៦ ស្មើនឹង ២៥,២% បន្ទាប់មកគឺអាជីវកម្មលក់គ្រឿងទេសនិងភេសជ្ជៈមានចំនួន ២២០៥គ្រួសារ ស្មើនឹង ១៧,៧% ឈរនៅលំដាប់ទីបីមុខរបរអាជីវកម្មម៉ាស៊ីនកិនស្រូវ គឺមានចំនួន២០០៦គ្រួសារ ស្មើ ១៦,១% ចំណែកឯការប្រកបរបរអាជីវកម្មបិតស្រាក៏មានច្រើនគួរសមដែរគឺ ១៤១០គ្រួសារ ស្មើនឹង ១១,៣% ។

## គ. ចំនួនគ្រួសារប្រកបអជីវកម្មចម្បងមានពី ២% ទៅ ១០% ប្រៀបធៀបសរុបក្នុងខេត្ត




រូបភាពទី(៣៦) បង្ហាញថាគ្រួសារប្រកបរបរអាជីវកម្មជួសជុលម៉ូតូមានចំនួន១០២៤គ្រួសារ (៨,២%) អាជីវកម្មកាត់សក់ ឬអ៊ុតសក់មានចំនួន ១០២៤គ្រួសារ (៥,៦%) គ្រួសារប្រកបរបរអាជីវកម្មលក់គ្រឿងសំណង់មានចំនួន៣១៤គ្រួសារ (២,៥%) ចំណែកឯគ្រួសារប្រកបរបរអាជីវកម្មលក់ថ្នាំពេទ្យ និងផ្សេងៗ មានចំនួន២៩៥គ្រួសារ (២,៤%) និងគ្រួសារប្រកបរបរអាជីវកម្មកាត់កញ្ចក់និងជាងដែកមានចំនួន ២៤៩គ្រួសារ ស្មើនឹង២%។

### ឃ. ចំនួនគ្រួសារប្រកបអាជីវកម្មចម្បងតិចជាង ២% ប្រៀបធៀបសរុបនៅទូទាំងខេត្ត

រូបភាពទី(៣៧) ចំនួនគ្រួសារដែលប្រកបអាជីវកម្មចម្បង




រូបភាពទី(៣៧) បង្ហាញថាគ្រួសារប្រកបរបរអាជីវកម្មជាស្ថានីយ៍ចាក់ប្រេងឥន្ធនៈមានចំនួន ២៣០គ្រួសារ (១,៨%) អាជីវកម្មជួសជុលគ្រឿងអេឡិចត្រូនិចមានចំនួន ១៩៣គ្រួសារ (១,៦%) គ្រួសារប្រកបរបរអាជីវកម្មជួសជុលរថយន្តមានចំនួន១១៩គ្រួសារ (១%) ចំណែកឯគ្រួសារប្រកបរបរអាជីវកម្មផ្ទះសំណាក់មានចំនួន ៨៨គ្រួសារ (០,៧%) គ្រួសារប្រកបរបរអាជីវកម្មជួសជុលឧបករណ៍ និងគ្រឿងម៉ាស៊ីនកសិកម្មមានចំនួន ៧៦គ្រួសារ (០,៦%) គ្រួសារប្រកបរបរអាជីវកម្មផលិតគ្រឿងសង្ហារឹម មាន ៦០គ្រួសារ (០,៥%) គ្រួសារប្រកបរបរអាជីវកម្មបើកភោជនីយដ្ឋានមានចំនួន ៤៥គ្រួសារ (០,៤%) និងចុងក្រោយគេគ្រួសារប្រកបរបរអាជីវកម្មបើកជាសណ្ឋាគាមានចំនួន ៨ គ្រួសារ ស្មើនឹង ០,១% គឺមានចំនួនតិចជាងគេបើប្រៀបធៀបទៅនឹងមុខរបរអាជីវកម្មចម្បងសរុបនៅក្នុងខេត្តស្វាយរៀង។

## ២.៨ វិស័យអប់រំ និងសេវាសង្គម

### ២.៨.១. ផ្នែកសិក្សាអប់រំ

នៅផ្នែកសិក្សាអប់រំក្នុងអត្ថបទនេះគឺសំដៅលើចំនួននិងចម្ងាយពីទីតាំងភូមិទៅកន្លែងផ្តល់សេវាអប់រំដល់ប្រជាពលរដ្ឋនៅទូទាំងខេត្តស្វាយរៀង។ មានសាលាមត្តេយ្យសិក្សាសហគមន៍ សាលា

មត្តេយ្យសិក្សា សាលាបឋមសិក្សា សាលាអនុវិទ្យាល័យ វិទ្យាល័យ និងសាកលវិទ្យាល័យរដ្ឋ (ទាំងរដ្ឋ និងឯកជន)។

**ក. ចំនួនគ្រឹះស្ថានសិក្សា**




រូបភាពទី( ៣៨ ) បានបង្ហាញពីចំនួនគ្រឹះស្ថានសិក្សាតាមកម្រិតលំដាប់លំដោយ ចាប់ពីមត្តេយ្យសិក្សារហូតដល់សាកលវិទ្យាល័យរបស់រដ្ឋនិងឯកជននៅទូទាំង **ខេត្តស្វាយរៀង** មានមត្តេយ្យសិក្សាចំនួន ៤៣០កន្លែង និងមានបឋមសិក្សាចំនួន ៣២៧កន្លែង ហើយមានអនុវិទ្យាល័យចំនួន ១៣៣កន្លែង និងមានវិទ្យាល័យចំនួន ៨០កន្លែង ហើយនៅខេត្តស្វាយរៀងមានសាកលវិទ្យាល័យចំនួន ៤៨កន្លែងផងដែរ។

## ខ.ចំនួនគ្រឹះស្ថានសិក្សា(មត្តេយ្យសិក្សានិងបឋមសិក្សា)តាមវិស័យរដ្ឋ ឯកជន និងសហគមន៍



រូបទី( ៣៩ ) ចំនួនសាលាមត្តេយ្យសិក្សា និងបឋមសិក្សា

រូបភាពទី( ៣៩ ) បានបង្ហាញពីចំនួនគ្រឹះស្ថានសិក្សាទៅតាមវិស័យនីមួយៗរបស់រដ្ឋ ឯកជន និងសហគមន៍នៅទូទាំង **ខេត្តស្វាយរៀង** មានគ្រឹះស្ថានសិក្សារបស់រដ្ឋចំនួន ៥៥៨កន្លែង និងមានគ្រឹះស្ថានសិក្សារបស់ឯកជនចំនួន ០៨កន្លែង ហើយក៏មានគ្រឹះស្ថានសិក្សារបស់សហគមន៍ ចំនួន ១៩១កន្លែងផងដែរ(សូមបញ្ជាក់ថាគ្រឹះស្ថានសិក្សារបស់សហគមន៍គឺមានត្រឹមតែកម្រិតមត្តេយ្យសិក្សាសហគមន៍ទេ) ។

## គ. ចំនួនគ្រឹះស្ថានសិក្សា(អនុវិទ្យាល័យ វិទ្យាល័យ និងខ្ពស់ជាង) តាមវិស័យ រដ្ឋ និងឯកជន



រូបទី( ៤០ ) ចំនួនសាលាអនុវិទ្យាល័យវិទ្យាល័យ និងខ្ពស់ជាង

រូបភាពទី( ៤០ ) បានបង្ហាញពីចំនួនគ្រឹះស្ថានសិក្សាតាមវិស័យរបស់រដ្ឋនិងឯកជននៅទូទាំង **ខេត្តស្វាយរៀង** មានចំនួនគ្រឹះស្ថានសិក្សា(អនុវិទ្យាល័យ វិទ្យាល័យ និងខ្ពស់ជាង)របស់រដ្ឋចំនួន ២៦០កន្លែង និងមានចំនួនគ្រឹះស្ថានសិក្សារបស់ឯកជនចំនួន ០១កន្លែងផងដែរ។

## ២.៩. ការស្ថាបនាផ្លូវគមនាគមន៍

នៅក្នុងផ្នែកផ្លូវគមនាគមន៍ក្នុងអត្ថបទនេះគឺសំដៅលើទីតាំងដែលបានស្ថាបនាផ្លូវគមនាគមន៍ជូនដល់ប្រជាពលរដ្ឋនៅក្នុងខេត្តស្វាយរៀង។

រូបភាពទី( ៤១ ) ប្រវែងផ្លូវថ្នល់ដែលបានស្ថាបនាតាមប្រភេទ (គិតជាគីឡូម៉ែត)




រូបភាពទី( ៤១ ) បានបង្ហាញអំពីការស្ថាបនាផ្លូវថ្នល់នៅទូទាំង **ខេត្តស្វាយរៀង** បានស្ថាបនាផ្លូវថ្នល់ដីប្រវែង ៦៩២គីឡូម៉ែត្រ និងបានស្ថាបនាផ្លូវថ្នល់គ្រួសប្រវែង៣២៥គីឡូម៉ែត ហើយបានស្ថាបនាផ្លូវថ្នល់ក្រាលកៅស៊ូប្រវែង ៥៨គីឡូម៉ែត។

## ២.១០. សុខាភិបាល

### ២.១០.១. សេវាកម្មសុខភាព

នៅផ្នែកសុខាភិបាលក្នុងអត្ថបទនេះគឺសំដៅលើទីតាំងដែលបានផ្តល់សេវាផ្នែកសុខាភិបាល និងភាពទទួលបានសេវាកម្មសុខភាពរបស់ប្រជាពលរដ្ឋនៅក្នុង**ខេត្តស្វាយរៀង** ពីត្រីមាសទី០១ ឆ្នាំ ២០១៩ ដល់ ត្រីមាសទី០១ ឆ្នាំ២០២០ ។

## ក. សេវាកម្មសុខភាព




រូបភាពទី( ៤២ ) បានបង្ហាញអំពីចំនួនសេវាកម្មសុខភាពដល់ប្រជាពលរដ្ឋដែលរស់នៅទូទាំង **ខេត្តស្វាយរៀង** មានសេវាកម្មសុខភាពចំនួន ៧៣៦កន្លែង ក្នុងនោះមានមន្ទីរពេទ្យចំនួន ២៤៤កន្លែង និងមណ្ឌលសុខភាពចំនួន ៤៩២កន្លែង។

## ខ. បុគ្គលិកពេទ្យតាមកម្រិត




រូបភាពទី(៤៣) បានបង្ហាញអំពីចំនួនបុគ្គលិកពេទ្យតាមកម្រិតនៅទូទាំងខេត្តស្វាយរៀង មានបុគ្គលិកពេទ្យមធ្យមចំនួន ១៦៥នាក់ និងមានបុគ្គលិកគិលានុបដ្ឋាយិកាឬឆ្មបចំនួន ៦១នាក់ ហើយមានបុគ្គលិកវេជ្ជបណ្ឌិតចំនួន ៤៤នាក់ និងមានឆ្មបបុរាណ ០៩នាក់ ។

## គ. ភាពទទួលបានសេវាកម្មសុខភាព




រូបភាពទី(៤៤) បានបង្ហាញពីចំនួនអ្នកជំងឺដែលមកទទួលសេវា និងការព្យាបាលតាមមន្ទីរពេទ្យ មណ្ឌលសុខភាព វេជ្ជបណ្ឌិត ពេទ្យមធ្យម គិលានុបដ្ឋាយិកាឬឆ្មប និងឆ្មបបុរាណនៅទូទាំង **ខេត្តស្វាយរៀង** មានចំនួន ៥២,១៩១នាក់ ។

## ២.១០.២. ប្រេវ៉ាឡង់ជំងឺសំខាន់ៗ

### ក. ជម្ងឺគ្រុនចាញ់ និងជម្ងឺរបេង



រូបភាពទី( ៤៥ ) ករណីអ្នកកើតនិងស្លាប់ដោយជម្ងឺគ្រុនចាញ់និងជម្ងឺរបេង

រូបភាពទី( ៤៥ ) បានបង្ហាញថា៖ **ខេត្តស្វាយរៀង** មានអ្នកកើតជំងឺគ្រុនចាញ់សរុបចំនួន ៣៤ នាក់ ក្នុងនោះមាន ០១នាក់ បានស្លាប់បាត់បង់ជីវិត ហើយមានអ្នកកើតជំងឺរបេងសរុបចំនួន ១១០៤ នាក់ ក្នុងនោះមាន ៧១នាក់ បានស្លាប់បាត់បង់ជីវិត។

## ខ. អ្នកស្លាប់ដោយជំងឺគ្រុនចាញ់តាមភេទ




រូបភាពទី(៤៦) បានបង្ហាញថា៖ **ខេត្តស្វាយរៀង** មានអ្នកស្លាប់ដោយសារជម្ងឺគ្រុនចាញ់សរុបចំនួន ០១នាក់ ហើយមិនមានស្រ្តីស្លាប់ដោយសារជម្ងឺគ្រុនចាញ់ទេ។

## គ. អ្នកស្លាប់ដោយជំងឺរបេងតាមភេទ



រូបភាពទី(៤៧) បានបង្ហាញថាៈ **ខេត្តស្វាយរៀង** មានអ្នកស្លាប់ដោយសារជំងឺរបេងតាមភេទសរុបចំនួន ៧១នាក់ ក្នុងនោះមានប្រុស ៣៨នាក់បានស្លាប់ដោយសារជម្ងឺរបេង ។

## ឃ. អ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍




រូបភាពទី( ៤៨ ) បានបង្ហាញថាៈ **ខេត្តស្វាយរៀង** មានអ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍សរុបចំនួន ៦៧៦នាក់ ក្នុងនោះមាន ៣៨នាក់ បានស្លាប់បាត់បង់ជីវិតដោយសារជម្ងឺអេដស៍។

## ង. អ្នកស្លាប់ដោយជំងឺអេដស៍តាមភេទ




